# សិលាចារឹកមានប្រភពមកពីវត្តព្រះធាតុ K.៧៣ ឬ K.៧១៨

## ១- ព័ត៌មានទូទៅ

កាលដើមឡើយ វត្តព្រះធាតុនេះស្ថិតនៅក្នុងភូមិព្រះធាតុ ឃុំរលួស ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។ ចាប់ពីឆ្នាំ២០១១មក ទីតាំងនេះត្រូវកាត់បញ្ចូលក្នុងសង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញវិញ។ យោងតាមគេហទំព័រ https://cisark.mcfa.gov.kh បានឱ្យដឹងថាក្នុងបរិវេណអារាមនេះ មានព្រះវិហារចំនួនពីរ និងកសិន្ទុព័ទ្ធជុំវិញចំនួន១[1]។ ព្រះវិហារខាងត្បូង សាងសង់លើទីទួលប្រាសាទបុរាណ ដែលហៅថាទួលព្រះធាតុ។ ឈ្មោះព្រះធាតុនេះ តែងប្រទះឃើញនៅទីតាំងអតីតប្រាសាទបុរាណ ភាគច្រើនជាប្រាសាទព្រហ្មញ្ញសាសនា និងត្រូវកែមកជាទីតាំងពុទ្ធសាសនាវិញ។ ទីទួលនេះមានសំណល់ខឿនថ្មបាយក្រៀម មានផ្លូវចូលពីទិសខាងកើត។

បើតាមសំណេះសំណល់នៅទីតាំងនេះ បញ្ជាក់ថាទីតាំងនេះជាស្ថានសាសនាតាំងពីសម័យមុនអង្គរហូតមកដល់ចុងស.វ.ទី១២និងដើមស.វ.ទី១៣ ក្នុងរាជ្យព្រះបាទស្រីជ័យវរ្ម័នទេវទី៧។ ភស្ដុតាងសម័យមុនអង្គរ មានដូចជា៖ ផ្ដែររចនាបថសម្បូរព្រៃគុហ៍ចំនួន២ បំណែកថ្មថ្ងើមអណ្ដើកមួយចំនួនដែលមានទាំងស្នាណទ្រោនីផងដែរ និងសិលាចារឹកចំនួន២ផ្ទាំង។ ស្របនឹងភស្ដុតាងនេះ យើងក៏ឃើញមានទីតាំងសម័យមុនអង្គរសំខាន់ៗដែលនៅជុំវិញនោះ ដូចជាសំណល់ប្រាសាទនិងសិលាចារឹកនៅវត្តជើងឯក[2] គ្រាំងព្រះពុទ្ធដែលរកឃើញផ្ទាំងសិលាចារឹក[3] និងប្រាសាទវត្តប្រាសាទជាដើម។ ឯភស្ដុតាងសម័យអង្គរមានវត្ថុសិល្បៈជាច្រើនស្ថិតក្នុងរចនាបថបាយ័នដូចជា៖ តោ នាគ បង្កាន់ដៃនាគ ព្រះពុទ្ធរូបបល្ល័ង្កជាដើម។ នៅរវាងដើមពាក់កណ្ដាលទី២នៃស.វ.ទី១២ ក៏មានផ្ទាំងសិលាចារឹកមួយ

---

[1] សូមអានបន្ថែម៖ https://cisark.mcfa.gov.kh/core/showsite.php?id=115&keyword=

[2] សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/885

[3] បច្ចុប្បន្ននេះ ទីតាំងគ្រាំងព្រះពុទ្ធបានរងការបំផ្លាញអស់រូបរាងទៅហើយ ដោយសារការសាងសង់សំណង់បុរីលំនៅឋាន។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ផ្ទាំង រកឃើញនៅទួលអង្គក្រសាំងធ្មារ ដែលមានចុះកាលបរិច្ឆេទនាមហាសករាជឆ្នាំ ១០៨៤ ត្រូវនឹងគ្រិស្តសករាជឆ្នាំ១១៦២ ក្នុងរាជ្យព្រះបាទយសោវម៌្មទេវទី២ គឺជាភស្តុតាងបង្ហាញអំពីអត្ថិភាព នៃសាសនដ្ឋានតំបន់នោះផង[៤]។ គួរបញ្ជាក់ផងថា នៅទីតាំងនេះធ្លាប់ធ្វើកំណាយសង្គ្រោះ ដើម្បីជួសជុលប្រាសាទព្រះធាតុនេះផងដែរ ប៉ុន្តែគម្រោងជួសជុលនោះពុំបានសម្រេចចប់ចុងចប់ដើមនោះទេ។

នៅក្នុងអត្ថបទនេះ យើងនឹងលើកយកផ្ទាំងសិលាចារឹកមួយផ្ទាំងដែលមានចុះលេខសារពើភណ្ឌ K.៧៣ ឬ K.៧១៨ មកសិក្សា។ សិលាចារឹកនេះ ធ្លាប់បានសិក្សាចុះផ្សាយរួចមកហើយ គឺនៅឆ្នាំ១៩៥៤ លោកសាស្ត្រាចារ្យ ហ្សក សេដែស បានចុះផ្សាយសិលាចារឹកនេះក្នុងសៀវភៅសិលាចារឹកនៃប្រទេសកម្ពុជា ក្បាលទី៦ ទំព័រទី៣៧ ប៉ុន្តែពុំមានការបកប្រែនោះទេ។ ក្នុងអត្ថបទនោះ លោកបញ្ជាក់ថាសិលាចារឹកនេះរកឃើញនៅវត្តព្រះធាតុ ក្បែរស្ទឹងព្រែកត្នោត ស្ថិតក្នុងស្រុកកណ្ដាលស្ទឹង ខេត្តកំពង់ស្ពឺ និងចុះលេខបញ្ជីសារពើភណ្ឌ K.៧៣។ នៅក្នុងឆ្នាំដដែល លោកក៏បានសិក្សាសិលាចារឹកនេះម្ដងទៀត ចុះផ្សាយក្នុងសៀវភៅតែមួយ នៅទំព័រ៥២ លោកបានចុះលេខបញ្ជីសិលាចារឹកនេះ K.៧១៨ ដោយដាក់ប្រភពសិលាចារឹកនេះមកពីទីតាំងមួយឈ្មោះពពេល ស្ថិតនៅក្នុងខេត្តតាកែវទៅវិញ។ សិលាចារឹកនេះនាំមករក្សាទុកនៅសារមន្ទីជាតិ នៅឆ្នាំ១៩៣២។ នៅឆ្នាំ១៩៧០ បានយកទៅរក្សាទុកនៅអភិរក្សដ្ឋានអង្គរ និងដឹកមករក្សាទុកក្នុងព្រះបរមរាជវាំងនៅឆ្នាំ ១៩៩៣ ទើបយកមករក្សាទុកនៅសារមន្ទីរជាតិជាថ្មីម្ដងទៀតក្នុងឆ្នាំ២០០២ និងរក្សាទុករហូតមកដល់បច្ចុប្បន្ន។

អត្ថបទចារឹកចារនៅលើថ្មស្រទាប់ មានកម្ពស់៦៥ស.ម. បន្ទារ២៤ស.ម. និងមានកម្រាស់៨ស.ម.។ សិលាចារឹកនេះពុំមានចុះកាលបរិច្ឆេទទេ ប៉ុន្តែយោងតាមតួអក្សរ គួរតែជាអត្ថបទស្ថិតក្នុងស.វ.ទី៧នៃគ.ស.។ អត្ថបទសរុបមានចំនួន១៥បន្ទាត់ ប៉ុន្តែពុំពេញ

---

[៤] សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/19586 និង https://ams.com.kh/khmercivilization/detail/20098

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

លេញនោះទេ ដ្បិតមានការបាក់បែកខូចខាតដោយអន្ទើ ដែលនាំឱ្យដាច់សេចក្តីខ្វះៗ។ អត្ថន័យរបស់សិលាចារឹកនេះ គឺជាបញ្ជីរៀបរាប់អំពីតង្វាយថ្វាយចំពោះព្រះដោយម្ចាស់បុណ្យ មានអ្នកបម្រើប្រុសស្រី ស្រែ និងគោក្របី។

## ២- អត្ថបទដើមជាអក្សរខ្មែរទំនើប

១- [[អំនោយិជំនូនិ[៥]]]តយជមាន[[តវ្រះ[៦]]]

២- [[បុណ្យ[៧]]]ម្រតាញិចរន្តក្ញោញិប៉ោំ------

៣- ---តវ្រះនក្កយជមានត(វ្រះក្នុំ)[[វ្រះវា]]

៤- --លវាត្បូវ៑១វាក្មោចិ១វាអនិស១កុ--

៥- --១កុក្និំ១កុត្មានិ១កុវ្រៀ១កុវ៉ាំតេង៑

៦- -ស្រេព្វយិតេំស្វាង៑+ស្រេព្វយិបិង៑

៧- ម្រសោយិ+ស្រេព្វយិល្វាង៑ចារ+ស្រេ

៨- អំនោយិបោញិអទិតិព្វយិវ្រះបាទ១

៩- ស្រេអំវិតបោញិក្មុន្ទអំនោយិបោ

១០- ញិសុទេវព្វយិតវ្រះបាទ១ត្នុរ៑

១១- ២០ក្រលា[៨]១តោង៑តេំ១០ស្រេព្វ

១២- យិអំវេក្ញោញិអំវិតវោ--

១៣- ម្រសិរ៑បាទ១ស្រេព្វយិ--

១៤- ចំបោកិអម្ទិតកុរាកិ[[ម្រសិ]]

១៥- រ៑បាទ០

---

[៥] សំណើលោក ហ្វី លីពចេណ្ណឺរ។

[៦] សំណើលោក ហ្វី លីពចេណ្ណឺរ។

[៧] សំណើលោក ហ្វី លីពចេណ្ណឺរ។

[៨] ពាក្យត្រឹមត្រូវ ប្រហែលជា «ក្របិ» ប៉ុន្តែអ្នកចារអាចច្រឡំទើបចារជា «ក្រលា» វិញ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## ៣- អត្ថបទប្រែសម្រួល

(១-៣) តង្វាយជំនូនរបស់យជមានគឺម្ចាស់បុណ្យ ថ្វាយចំពោះព្រះ គឺជាបុណ្យរបស់ម្រតាញចវន្ត ជាក្មោញ(មេ)ប៉ោ---ថ្វាយចំពោះព្រះនិង់ជាអ្នកយជមានចំពោះព្រះ។

(៣-៥) អ្នកបម្រើព្រះ វា--ល វាត្បូវ១ វាក្មោច១ វាអនិស១ កុ----១ កុក្ញុំ១ កុត្មាន១ កុព្រៀ១ កុវ៉ាំតេង១។

(៦-១៥) ស្រែនៅឯដើមស្វែង ស្រែនៅឯបឹងម្រសោយ ស្រែនៅឯល្ងាំងចារ ស្រែដែលជាអំនោយបោញអទិតថ្វាយដល់ព្រះបាទ ស្រែបានពីបោញក្ននជាអំណោយបោញសុទេវថ្វាយចំពោះព្រះបាទ។ គោ២០ក្បាល ក្របី១ក្បាល ដើមដូង១០ដើម។ ស្រែនៅឯអង្វេក្មោញបានពីបោញម្រសិរ១បាទ។ ស្រែនៅឯ--ចំបក់បានពីកុរាកម្រសិរ។

### បញ្ជីឯកសារ

Cœdès, George. (1954). Inscription du Vằt Práḥ Thãt. In *Inscription du Cambodge* (Vol. VI, pp. 37 & 52). Paris: Editions de Boccard.

### គេហទំព័រ

http://sealang.net/ok/corpus.htm

https://ams.com.kh/khmercivilization/detail/20098

https://ams.com.kh/khmercivilization/detail/19586

https://ams.com.kh/khmercivilization/detail/885

https://cisark.mcfa.gov.kh/core/showsite.php?id=115&keyword=

អត្ថបទដោយៈ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព



ផ្តែរនៅវត្តព្រះធាតុ (រូបថត៖ CISARK)



ផ្តែរនៅវត្តព្រះធាតុ (រូបថត៖ CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សំណល់បុរាណវត្ថុនៅវត្តព្រះធាតុ (រូបថត៖ CISARK)



សំណល់បុរាណវត្ថុនៅវត្តព្រះធាតុ (រូបថត៖ CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សំណល់បុរាណវត្ថុនៅវត្តព្រះធាតុ (រូបថត៖ CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សិលាចារឹក K.៧៣ ឬ K.៧១៨ (រូបថត៖ CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



n. 914 / K. 73

សិលាចារឹក K.៧៣ ឬ K.៧១៨ (រូបថតៈ CISARK)

អត្ថបទដោយៈ ហ៊ុន ឈុនតេង